**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**


មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ខេត្តកំពង់ធំ
ចូល
មកដល់ថ្ងៃទី ១៦-០៣-២០១៨
ម៉ោង: ៩:៣០
លេខ: ៥១៩
បញ្ជូន:


# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍ព្រះគន្លង
# ២០១៨ ~ ២០២០

ភូមិ ៖ ទួលនាងសាវ

ឃុំ ៖ ផាត់សណ្ដាយ

ស្រុក ៖ កំពង់ស្វាយ

ខេត្ត ៖ កំពង់ធំ

# មាតិកា


១. ស្ថានភាពទូទៅ............ ១
២. អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ច ............ ១
ក. ប្រជាពលរដ្ឋ............ ១
ខ. មុខរបរ ............ ១
ខ.១. អ្នកដែលមានមុខរបរនេសាទ និងធ្វើអាជីវកម្មផ្សេងៗ ............ ២
ខ.២. អ្នកដែលមានមុខរបរធ្វើអាជីវកម្ម ប៉ុន្តែមិនធ្វើនេសាទ ............ ២
៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ............ ២
ក. ទីតាំង ............ ៣
ខ. ដែននេសាទ............ ៣
ខ.១. បឹង ............ ៣
ខ.២. ត្រពាំង............ ៣
ខ.៣. ថ្លុក ............ ៤
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស............ ៤
ឃ. ធនធានជលផល............ ៤
ឃ.១. ប្រភេទត្រី............ ៥
ឃ.២. ប្រភេទវារីសត្វ ............ ៥
ឃ.៣. ប្រភេទបក្សី............ ៥
ឃ.៤. ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ............ ៥
៤. ការធ្វើនេសាទ............ ៥
ក. អ្នកនេសាទ ............ ៥
ខ. ឧបករណ៍នេសាទ............ ៦
គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ............ ៨
៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍............ ៨
ក. ទស្សនៈវិស័យ ............ ៨
ខ. គោលបំណង............ ៨
គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ............ ៨
គ.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ ............ ៨
គ.២. ផែនការកែលំអដែននេសាទ............ ១១
គ.៣. ផែនការរៀបចំកន្លែងអភិរក្ស ............ ១២
គ.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក............ ១៣
គ.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ............ ១៤
គ.៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ............ ១៥
គ.៧. ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ ............ ១៥
គ.៧.១.ក្រុមសន្សំ............ ១៥

គ.៨. ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ........ ១៦
គ.៩. ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និង លិខិតបទដ្ឋានពាក់ព័ន្ធ ........ ១៧
គ.១០.ផែនការសង់ស្នាក់ការ និងផ្លូវសហគមន៍នេសាទ ........ ១៧
គ.១១. ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ ១៨
គ.១២. ផែនការពង្រឹងបណ្តាញសហគមន៍នេសាទ និងចូលរួមប្រជុំផ្សេងៗ ........ ១៨
ឃ. យុទ្ធសាស្ត្រ ........ ១៩
៦. ឧបសម្ពន្ធ ........ ២០
ឧបសម្ពន្ធ៖តារាង សង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ ២០១៧-២០២២ ........ ២១
ឧបសម្ពន្ធ៖តារាងកម្មវិធីការងារឆ្នាំ ២០១៧-២០២២ ........ ២២

# ផែនការគ្រប់គ្រងសហគមន៍នេសាទព្រះគន្លង

## ១. ស្ថានភាពទូទៅ

នៅឆ្នាំ២០០០ រដ្ឋបាលជលផលបានធ្វើកំណែទម្រង់ ដើម្បីឲ្យសមស្របជាមួយគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ដែលជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រ ដោយផ្ទេរសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់ជនបទ ដើម្បីចូលរួមគ្រប់គ្រងធនធានជលផលនៅក្នុងមូលដ្ឋានរបស់ខ្លួន ប្រកបដោយចីរភាព និងសមធម៌ តាមបែបសហគមន៍នេសាទ ក្នុងគោលបំណងទទួលផលប្រយោជន៍ និងធ្វើអោយធនធានជលផល ប្រសើរឡើងក្នុងមូលដ្ឋានរបស់ខ្លួន។

សហគមន៍នេសាទព្រះគន្លង ត្រូវបានរៀបចំសហគមន៍នេសាទ ដោយមានការចូលរួមយ៉ាងកុះករពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងទទួលបានការគាំទ្រពីគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ជំនាញជលផល និងកិច្ចសហការពីអាជ្ញាធរដែនដី។ សហគមន៍នេសាទព្រះគន្លង ត្រូវបានបង្កើតឡើងដោយមហាសន្និបាត លើកដំបូងនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៧ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧។

សហគមន៍នេសាទព្រះគន្លង មានទីតាំងស្ថិតនៅក្នុងភូមិទួលនាងសាវ ឃុំផាត់សណ្តាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលមានសមាជិកសរុបចំនួន ២៩៩នាក់ ស្រីចំនួន ៨៦នាក់ និងមានគណៈកម្មការចំនួន ០៥នាក់ ស្រី០០នាក់ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន ១១៥គ្រួសារ។

កន្លងមកសហគមន៍នេសាទព្រះគន្លង នេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួនរួមមាន៖

- ប្រមូលប្រាក់ភាគទានសមាជិកភាព
- ចុះល្បាត ប្រជុំប្រចាំខែ ផ្សព្វផ្សាយពីច្បាប់លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុង
- សហការជាមួយស្ថាប័នជំនាញ និងអាជ្ញាធរពាក់ព័ន្ធក្នុងការទប់ស្កាត់បទល្មើសនេសាទ ដែលកើតមានក្នុងសហគមន៍។

## ២. អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ច

### ក. ប្រជាពលរដ្ឋ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន៤៧៣នាក់ ប្រុស២២១នាក់ ស្រី២៥២នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន៤៧៣នាក់។
- ចំនួនស្ត្រីមេម៉ាយសរុបក្នុងសហគមន៍នេសាទមាន១៧នាក់
- ចំនួនជនពិការសរុបក្នុងសហគមន៍នេសាទមាន ០៦នាក់ ប្រុស០៦នាក់ ស្រី០០នាក់
- ចំនួនចាស់ជរាសរុបក្នុងសហគមន៍នេសាទមាន ១៥នាក់ ប្រុស០០នាក់ ស្រី១៥នាក់
- ចំនួនកុមារកំព្រាសរុបក្នុងសហគមន៍នេសាទមាន ០២នាក់ ប្រុស០០នាក់ ស្រី០២នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃសរុបក្នុងសហគមន៍នេសាទមាន ០៦នាក់ ប្រុស០១នាក់ ស្រី០៥នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ១០០%

ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់

- អ្នកមិនចេះអក្សរមានចំនួន២៧០នាក់ ប្រុស១០០នាក់ ស្រី១៧០នាក់
- កម្រិតថ្នាក់បឋមសិក្សាមានចំនួន១៩៧នាក់ ប្រុស១០០នាក់ ស្រី៩៧នាក់
- កម្រិតថ្នាក់មធ្យមសិក្សាមាន ចំនួន០០នាក់ ប្រុស០០នាក់ ស្រី០០នាក់
- កម្រិតថ្នាក់ឧត្តមសិក្សាមាន ចំនួន០០នាក់ ប្រុស០០នាក់ ស្រី០០នាក់

## ២. មុខរបរ

តាមរបាយការណ៍ និង ឯកសារឃុំ បានបញ្ជាក់ថា នៅក្នុងសហគមន៍ព្រះគន្លង មានប្រជាពលរដ្ឋសរុបចំនួន ៣១០ គ្រួសារ ដែលពឹងផ្អែកលើការនេសាទ និងការចិញ្ចឹមត្រី រីឯស្ត្រីគ្រាន់តែជាអ្នកប្រកបមុខរបរបន្ទាប់បន្សំដូចជាកែច្នៃផលនេសាទ ផ្តល់ចំណីត្រី និងលក់ដូរជាដើម។ ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពចំបង ដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេសបានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។ កន្លងមករដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍ បានជួយបណ្តុះបណ្តាល អំពីបច្ចេកទេសការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងៗទៀត ដល់សមាជិកសហគមន៍នេសាទ ដើម្បីចូលរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឲ្យមានភាពរីកចំរើន។ ពេលបច្ចុប្បន្ន នៅក្នុងសហគមន៍នេសាទព្រះគន្លង ប្រជាពលរដ្ឋមានស្ថានភាពនៃការចិញ្ចឹមជីវិតនិងមុខរបរសំខាន់ៗរួមមាន៖

### ២.១. អ្នកដែលមានមុខរបរនេសាទ និងធ្វើអាជីវកម្មផ្សេងៗ

- ជាអ្នកនេសាទ អ្នកចិញ្ចឹមសត្វលក្ខណៈគ្រួសារ និងដាំបន្លែមានចំនួន ៩៨ គ្រួសារ
- ប្រមូលទិញ លក់ផលត្រី និងនេសាទមានចំនួន ៣ គ្រួសារ
- ជាអ្នកចិញ្ចឹមត្រីរ៉ស់ ចិញ្ចឹមសត្វលក្ខណៈគ្រួសារ និងនេសាទចំនួន ១៤៥ គ្រួសារ
- ជាអ្នកចិញ្ចឹមត្រីអណ្តែង ចិញ្ចឹមសត្វលក្ខណៈគ្រួសារ និងនេសាទចំនួន ២៥ គ្រួសារ
- អ្នកកែច្នៃផលត្រី និងនេសាទដូចជា៖ ធ្វើផ្អក ប្រហុក និងត្រីឆ្អើរ មានចំនួន ៧ គ្រួសារ
- រត់ទូកដរ និងនេសាទមានចំនួន ០២ គ្រួសារ
- គ្រូបង្រៀន និងនេសាទ ០៣ គ្រួសារ។

### ២.២. អ្នកដែលមានមុខរបរធ្វើអាជីវកម្ម ប៉ុន្តែមិនធ្វើនេសាទ

- អ្នកលក់ដូរ ៦គ្រួសារ
- ជាងធ្វើម៉ាស៊ីនកាណូត ០២គ្រួសារ។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

### ក. ទីតាំង

សហគមន៍នេសាទព្រះគន្លង មានទីតាំងស្ថិតក្នុងភូមិព្រះគន្លង ជាដែននេសាទសាធារណៈរបស់រដ្ឋ ដែលត្រូវបានកាត់ចេញពីឡូត៍នេសាទលេខ១ និងជាដែននេសាទទឹកសាបក្នុងខេត្តកំពង់ធំ។ កន្លែងនេសាទសហគមន៍នេះ មានទំហំ ៤៩៦៩ហិកតា ហើយមានបឹងចំនួន១៦ ត្រពាំងចំនួន០៧ ថ្លុកចំនួន០៣ ។ ត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ហើយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រកាសទទួលស្គាល់នៅថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៨ ។

សហគមន៍នេសាទព្រះគន្លង មានព្រំប្រទល់ ៖

- ខាងជើងទល់ នឹងស្ទឹងសែន
- ខាងត្បូងទល់នឹងក្អែកដំបង
- ខាងកើតទល់នឹងសហគមន៍នេសាទកំពង់គោ
- ខាងលិចទល់នឹងបឹងធំ។

## ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ព្រះគន្លង មានវិសាលភាពនៅក្នុងបឹងទន្លេសាប ដែលគ្របដណ្តប់លើកន្លែងអភិរក្សពូជត្រី ព្រៃក ត្រពាំង និងអន្លង់សំខាន់ៗ មួយចំនួនដូចជា៖

### ខ.១. បឹង

| ល.រ | ឈ្មោះបឹង | ទំហំជា ហិត | រដូវនេសាទ |
|---|---|---|---|
| ១ | បឹងទទឹងថ្ងៃ | ១១,២៣ | ខែមករា ដល់ ខែធ្នូ |
| ២ | បឹងអាត្រាវ | ២,៥០ | ខែមករា ដល់ ខែធ្នូ |
| ៣ | បឹងអាកំបុត | ០,៨៩ | ខែមករា ដល់ ខែធ្នូ |
| ៤ | បឹងក្រពើសម | ៦,២៦ | ខែមករា ដល់ ខែធ្នូ |
| ៥ | បឹងក្រពើពួយ | ៦,៥៨ | ខែមករា ដល់ ខែធ្នូ |
| ៦ | បឹងខ្វែងអាស្តរ | ២០,២៣ | ខែមករា ដល់ ខែធ្នូ |
| ៧ | បឹងអាត្រាព្រួល | ៧,២២ | ខែមករា ដល់ ខែធ្នូ |
| ៨ | បឹងអាខ្វាក់ធំ | ១,១៧ | ខែមករា ដល់ ខែធ្នូ |
| ៩ | បឹងមោង | ៧,៦២ | ខែមករា ដល់ ខែធ្នូ |
| ១០ | បឹងប្រវឹក | ១១,៦៨ | ខែមករា ដល់ ខែធ្នូ |
| ១១ | បឹងព្រលិត | ៤,១៣ | ខែមករា ដល់ ខែធ្នូ |
| ១២ | បឹងរាំងកោង | ៣,៩៩ | ខែមករា ដល់ ខែធ្នូ |
| ១៣ | បឹងក្រពើគ្រហឹម | ៤,២៥ | ខែមករា ដល់ ខែធ្នូ |
| ១៤ | បឹងព្រះគន្លង | ៧៩,៥១ | ខែមករា ដល់ ខែធ្នូ |
| ១៥ | បឹងអន្លង់រាជ | ៥១,២៦ | ខែមករា ដល់ ខែធ្នូ |
| ១៦ | បឹងកក់ | ១០,១២ | ខែមករា ដល់ ខែធ្នូ |

### ខ.២. ត្រពាំង

| ល.រ | ឈ្មោះត្រពាំង | ទំហំជា ហិត | រដូវនេសាទ |
|---|---|---|---|
| ១ | ត្រពាំងអាក្អុត | ១,៦ | ខែមករា ដល់ ខែធ្នូ |
| ២ | ត្រពាំងជាន់អន្លង់ | ០,៩៥ | ខែមករា ដល់ ខែធ្នូ |
| ៣ | ត្រពាំងថ្លុកឆេង | ០,៨៥ | ខែមករា ដល់ ខែធ្នូ |
| ៤ | ត្រពាំងថ្លុកតាសែង | ១,៥៥ | ខែមករា ដល់ ខែធ្នូ |
| ៥ | ត្រពាំងថ្លុកតាកែវ | ២,០៥ | ខែមករា ដល់ ខែធ្នូ |
| ៦ | ត្រពាំងថ្លុកជឿន | ០,២២ | ខែមករា ដល់ ខែធ្នូ |
| ៧ | ត្រពាំងថ្លុកតារ៉េន | ០,២៦ | ខែមករា ដល់ ខែធ្នូ |

### ខ.៣. ថ្លុក

| ល.រ | ឈ្មោះថ្លុក | ទំហំជា ហិត | រដូវនេសាទ |
|---|---|---|---|
| ១ | ថ្លុកតាលី | ១ | ខែមករា ដល់ ខែធ្នូ |
| ២ | ថ្លុកតារ៉េន | ១,៤៩ | ខែមករា ដល់ ខែធ្នូ |

| | | | |
|---|---|---|---|
| ៣ | ថ្លុកតាឈួន | ១,២៩ | ខែមករា ដល់ ខែធ្នូ |
| ៤ | ព្រៃលិចទឹក | ៣៧៧៧,៥៣ | |
| ៥ | ដីនាបលិចទឹក | ៧២៨,៦៣ | |

កន្លែងនេសាទសហគមន៍ព្រះគន្លង បានផ្តល់នូវលក្ខណៈងាយស្រួលដល់ការរស់នៅ និងការធ្វើអាជីវកម្មនេសាទ នៅក្នុងសហគមន៍ ក៏ដូចអ្នកមកពីខាងក្រៅសហគមន៍ ជាពិសេសកន្លែងនេសាទសហគមន៍ មានអំណោយផលល្អ ដល់ការរស់នៅរបស់ពពួកវារីសត្វ រុក្ខជាតិ និងជាប្រភពចំណី ជម្រកពងកូនរបស់មច្ឆា សត្វស្លាប និងសត្វល្មូនគ្រប់ប្រភេទ។ ម៉្យាងទៀត កន្លែងនេសាទសហគមន៍ព្រះគន្លង ជាក់ស្តែងបានភ្ជាប់ជាមួយបឹង ត្រពាំង ថ្លុក ព្រៃលិចទឹក និងដីទំនាបលិចទឹក ដែលទទួលរបបទឹកពីបឹងទន្លេសាប ហើយបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់កសិកម្ម។

ដែននេសាទសំខាន់ៗនៅក្នុងសហគមន៍ព្រះគន្លង មានបឹងចំនួន១៦ ដែលមានទំហំប្រមាណ ៦,៣៥ហិកតា និងត្រពាំងមានចំនួន០៧ ដែលមានទំហំប្រមាណ១២,៧៣ហិកតា។ ដោយឡែក កន្លែងនេសាទសហគមន៍ព្រះគន្លងមានដូចជា៖ ព្រៃលិចទឹកមានទំហំប្រហែល ៣៧៧៧,៥៣ហិកតា ដីទំនាបលិចទឹកមានទំហំសរុប ៧២៨,៦៣ ហិកតា និងកន្លែងនេសាទមានទំហំប្រហែល ៤៩៦៩ហិកតា។

### គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

សហគមន៍នេសាទព្រះគន្លង បានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សចំនួន ០៣កន្លែង ដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ។ កន្លែងអភិរក្ស ត្រូវបានធ្វើការគ្រប់គ្រង ដោយសហគមន៍នេសាទ កន្លែងអភិរក្សត្រីមេពូជទាំងនេះមានដូចខាងក្រោម៖

| ល.រ | ឈ្មោះតំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស | ទំហំជា ហត | ប្រវែង |
|---|---|---|---|
| ១ | បឹងអាខ្វាក់ធំ | ១,១៦ | ប=១៥០ម x ទ=៨០ម |
| ២ | អន្លង់ទួល អន្លង់រាជ | ១ | ប=១០០ម x ទ=១០០ម |
| ៣ | អន្លង់អភិរក្សកោះមីនាង | ២ | ប=១៨០ម x ទ=១១០ម |

### ឃ. ធនធានជលផល

នៅក្នុងប្រទេសកម្ពុជា ធនធានជលផល បានដើរតួនាទីយ៉ាងសំខាន់ ក្នុងសន្តិសុខស្បៀង ដោយឡែកត្រីអាចផ្តល់ជាអាហារ ដល់ការចិញ្ចឹមជីវិត របស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ តាមការបង្ហាញពី សហគមន៍ព្រះគន្លង បានឱ្យដឹងថា នាពេលបច្ចុប្បន្ន ធនធានជលផលបានថយចុះ ជាពិសេសក្នុងឆ្នាំ២០១៥ ដោយសារមានការប្រែប្រួលអាកាសធាតុ ដែលធ្វើឱ្យបឹង ព្រែករីងរាក់ ហើយធ្វើឲ្យប្រភេទត្រីមេពូជ ត្រូវបាននេសាទយកស្ទើរតែទាំងអស់។ ផ្អែកតាមការអង្កេតរបស់ក្រុមការងារ សមាជិកសហគមន៍ ធនធានជលផល ក្នុងសហគមន៍នេសាទព្រះគន្លង មានដូចជា

### ឃ.១. ប្រភេទត្រី៖

ក្នុងសហគមន៍នេសាទព្រះគន្លង មានប្រភេទត្រីដូចជា៖ ត្រីរៀល ត្រីឆ្លាំង ត្រីកេះ ត្រីកញ្ចុះ ត្រីអាចម៍កុក ត្រីក្អែក ត្រីគ្រំ ត្រីចិន ត្រីឆ្កិន ត្រីកន្ទ្រប់ ត្រីប្រម៉ា ត្រីត្រសក់ ត្រីក្រាយ ត្រីក្រម៉ម ត្រីខ្ទឹង ត្រីខ្លា ត្រីរ៉ស់ ត្រីឆ្តោ ត្រីអណ្តែង ត្រីឆ្លូញ ត្រីចេកទុំ ត្រីកន្ធង ត្រីឆ្ពោក ត្រីកញ្ចុះភ្លោង ត្រីក្រពត ត្រីចង្វា ត្រីដំរី ត្រីកំផ្លៀញ ត្រីផ្ទក់ ត្រីអណ្តាតឆ្កែ ត្រីឆ្កៀត ត្រីក្លាំងហាយ ត្រីក្រាញ់ ត្រីព្រួល ត្រីស្លាបមាន់ ត្រីសង្កត់ប្រាក់ ត្រីក្រុះ ត្រីព្រួល ត្រីស្លាត ត្រីស្រកាត្នោត ត្រីកំភ្លៀវ ត្រីខ្មាន់ ត្រីគ្រុំ ត្រីដៀប ត្រីចង្វាមូល ត្រីក្លាំងហាយ ត្រីក្អែក ត្រីលិញ ។ល។

**ឃ.២. ប្រភេទវារីសត្វ:**

ក្នុងសហគមន៍នេសាទព្រះគន្លង មានប្រភេទវារីសត្វដូចជា៖ ក្តាម ខ្យង ខ្ចៅ គ្រំ លៀស អណ្តើក កន្ធាយ ពស់ កង្កែប ហ៊ីង គីង្គក់ អន្ទង់ ក្តាមទូក កន្ទេះឡង់ ក្រពើត្រី អន្សង់ ភេ សត្វស្វាក្រះ សំពោច ។ល។

**ឃ.៣. ប្រភេទបក្សី:**

ក្នុងសហគមន៍នេសាទព្រះគន្លង មានប្រភេទបក្សីដូចជា៖ ក្អែកទឹក សត្វគ្រៀល សត្វទោម សត្វទុង សត្វប្រវឹក សត្វក្រសា សត្វកុកស សត្វមាន់ទឹក សត្វទាព្រៃ សត្វទាទឹក សត្វអូត សត្វទុង សត្វស្មោញ សត្វសេក សត្វលលក សត្វចាប សត្វត្រយង សត្វនាលខ្យង សត្វត្រដក់ សត្វក្រសា សត្វកំពីងជូង។ល។

**ឃ.៤. ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ:**

ក្នុងសហគមន៍នេសាទព្រះគន្លង មានប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិដូចជា៖ ដើមរាំងទឹក ដើមតាអូរ ដើមអញ្ចាញ ដើមថ្ងាន់ ដើមកន្សែង ដើមបន្លាយួន ដើមស្នាចទឹក ដើមកណ្តាប់ចង្កេរ ដើមរំដេញ ដើមបន្លាស្អិត ។ល។

**៤. ការធ្វើនេសាទ**

នេសាទជាមុខរបរចាំបាច់ សម្រាប់ការចិញ្ចឹមជីវិតរបស់សមាជិកសហគន៍នេសាទព្រះគន្លង និងផលិតផលត្រូវបានធ្វើអាជីវកម្ម ក្នុងតំបន់ផ្ទាល់ ដើម្បីរកចំណូល ហើយបាននាំចេញមកទីក្រុង ព្រមទាំងបានធ្វើពាណិជ្ជកម្មក្រៅប្រទេសទៀតផង។ពេលបច្ចុប្បន្ន ប្រជាពលរដ្ឋទាំងអស់ក្នុងសហគមន៍នេះ បានផ្តោតលើកានេសាទដោយបានប្រើប្រាស់ឧបករណ៍លក្ខណៈគ្រួសារ ក្នុងការទាញយកផលនេសាទ ប៉ុន្តែការនេសាទរបស់សមាជិកសហគមន៍ និងអ្នកខាងក្រៅ ត្រូវបានអនុវត្តស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ ជាពិសេសផែនការគ្រប់គ្រងរបស់សហគមន៍នេសាទដែលបានរៀបចំសម្រាប់ឆ្នាំ២០១៨ ដល់ ឆ្នាំ២០២០។ ទោះបីជានៅមានជនល្មើសខ្លះ បានប្រើប្រាស់ឧបករណ៍ខុសច្បាប់នៅកន្លែងនេសាទសហគមន៍ព្រះគន្លង ជាពិសេសនៅក្នុងកំឡុងឆ្នាំ២០១៥ ដែលមានបញ្ហាគ្រោះរាំងស្ងួត បានធ្វើឱ្យបឹង និង ត្រពាំងរីងរាក់ ហើយប្រភេទត្រីមេពូជ ត្រូវបាននេសាទដោយជនល្មើស ។

តាមការសិក្សា និងប្រមូលទិន្នន័យពីក្រុមប្រឹក្សាឃុំ ភូមិ និងសហគមន៍នេសាទព្រះគន្លង បានបង្ហាញពីចំនួនអ្នកដែលពាក់ព័ន្ធ ក្នុងការធ្វើនេសាទក្នុងកន្លែងនេសាទសហគមន៍ព្រះគន្លង មានដូចខាងក្រោម៖

**ក. អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ២៩៩នាក់ ស្រី៥០នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នៅក្នុងសហគមន៍មានចំនួន ១៧៤នាក់ ស្រី៤០នាក់
- តាមការប៉ាន់ស្មាន អ្នកនេសាទដែលមកពីខាងក្រៅ ហើយមិនមែនជាសមាជិកសហគមន៍ព្រះគន្លង មានប្រហែល៥០០នាក់ ស្រី៧០នាក់ ក្នុង១ឆ្នាំ ។

**ខ. ឧបករណ៍នេសាទ**

នៅរដូវបើកនេសាទ ប្រជាពលរដ្ឋនៅក្នុងសហគមន៍នេសាទព្រះគន្លង និងអ្នកមកពីខាងក្រៅតែងតែធ្វើនេសាទដោយប្រើប្រាស់ ប្រភេទឧបករណ៍នេសាទលក្ខណៈគ្រួសារ ដូចជា៖ លប មង សន្ទូច លបព្រៀង ឡើ លាន់ និងជុច។ល។សមាជិកនិងគណៈកម្មការសហគមន៍នេសាទព្រះគន្លង បានធ្វើការប៉ាន់ប្រមាណពីតម្រូវការ ពីប្រភេទឧបករណ៍ដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រងសមាជិក និង គណៈកម្មការសហគមន៍នេសាទ បានស្នើសុំខណ្ឌរដ្ឋបាលជលផល ធ្វើការផ្សព្វផ្សាយច្បាប់ផលផលដល់ប្រជាពលរដ្ឋ ក្នុងសហគមន៍ព្រះគន្លង អោយបានទូលំទូលាយ និងអ្នកនេសាទខាងក្រៅ លើប្រភេទឧបករណ៍នេសាទ ដែលហាមឃាត់ដូចជា៖ ឧបករណ៍ឆក់ត្រី អ៊ុយស្បៃមុង។ល។

ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិក ដែលប្រើប្រាស់ក្នុងសហគមន៍ព្រះគន្លង មានដូចជា

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | មង | ដៃ | ៣-៧សម X ១-២ម | ១ឆ្នាំពេញ |
| ២ | សន្ទូចរនង | ផ្លែ | ១០០០ | ខែកញ្ញា ដល់ ខែមករា |
| ៣ | លបទល់ | ផ្លែ | ០,៦ម X ១,៦ម X ២,៥សម | ខែសីហា ដល់ ខែកុម្ភៈ |
| ៤ | លបលួង | គ្រឿង | ០,៣ម X ០,៧ម X ២,៥សម | ខែសីហា ដល់ ខែកុម្ភៈ |
| ៥ | ប៉ោង | គ្រឿង | ៥០ | ខែសីហា ដល់ ខែមីនា |
| ៦ | លាន់ | គ្រឿង | ០,៦ម - ១០សម X ១,៥ម | ខែសីហា ដល់ ខែធ្នូ |
| ៧ | អួន | វង់ | ២,៥សម X ៣ម X ២៥ម | ខែមករា ដល់ ខែមេសា |
| ៨ | អញ្ចង | វង់ | ៣សម X ៦ម | ខែមីនា ដល់ ខែឧសភា |
| ៩ | សំណាញ់ | វង់ | ៣សម X ៦ម | ខែមករា ដល់ ខែឧសភា |
| ១០ | សាង | ផ្លែ | ៨០ | ខែសីហា ដល់ ខែកុម្ភៈ |
| ១១ | ស្ទួ សម | គ្រឿង | ៥ម | ខែមីនា ដល់ ខែឧសភា |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ (គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន HYNOTA | ២០០ | ៣០០ - ១តោន | ៦ ដល់ ១៨ |
| ទូកអុំ ឬទូកចែវ | ១០០ | ១០០ | |

ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | មង | ដៃ | ៣-៧សម X ១-២ម | ខែកញ្ញា ដល់ ខែមីនា |
| ២ | សន្ទូចរនង | ផ្លែ | ២០០០ - ៣០០០ | ខែមករា ដល់ ខែធ្នូ |
| ៣ | លបទល់ | ផ្លែ | ០,៦ម X ១,៨ម X ២សម | ខែវិច្ឆិកា ដល់ ខែកុម្ភៈ |
| ៤ | ទ្បើ | លប | ០,៥ម X ០,៧ម X ៧០សម | ខែសីហា ដល់ ខែមករា |
| ៥ | លបលួង | គ្រឿង | ០,៣ម X ០,៧ម X ២,៥សម | ខែមីនា ដល់ ខែកក្កដា |
| ៦ | ដុច | គ្រឿង | ០,៣ម X ០,៧ម X ៣សម | ខែមីនា ដល់ ខែកក្កដា |
| ៧ | ប៉ោង | គ្រឿង | ៥០ | ខែវិច្ឆិកា ដល់ ខែកក្កដា |
| ៨ | លាន់ | គ្រឿង | ០,៦ម - ១០សម X ១,៥ម | ខែមិថុនា ដល់ ខែធ្នូ |
| ៩ | អួន | វង់ | ២,៥សម X ៣ម X ២៥ម | ខែមីនា ដល់ ខែមិថុនា |
| ១០ | អញ្ចង | វង់ | ៤០សម X ៦ម | ខែមេសា ដល់ ខែកក្កដា |
| ១១ | សំណាញ់ | វង់ | ៣សម X ៧ម | ខែមករា ដល់ ខែមិថុនា |
| ១២ | បបក់ | គ្រឿង | ៥០ | ខែកុម្ភៈ ដល់ ខែមិថុនា |
| ១៣ | ស្ទួ សម | គ្រឿង | ០,៨ម | ខែមិថុនា ដល់ ខែឧសភា |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ (គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន HYNOTA | ២០ | ៥០០ | ៦ ដល់ ១៨ |
| ទូកអុំ ឬទូកចែវ | ១០០ | ១០០ | |

ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | មង | ដៃ | ៣-៧សម X ១-២ម | ខែកញ្ញា ដល់ ខែមីនា |
| ២ | សន្ទូចរនង | ផ្លែ | ២០០០ - ៣០០០ | ខែមករា ដល់ ខែធ្នូ |
| ៣ | លបទល់ | ផ្លែ | ០,៦ម X ១,៨ម X ២សម | ខែវិច្ឆិកា ដល់ ខែកុម្ភៈ |
| ៤ | ទ្បើ | លប | ០,៥ម X ០,៧ម X ៧០សម | ខែសីហា ដល់ ខែមករា |
| ៥ | លបលួង | គ្រឿង | ០,៣ម X ០,៧ម X ២,៥សម | ខែមីនា ដល់ ខែកក្កដា |
| ៦ | ជុច | គ្រឿង | ០,៣ម X ០,៧ម X ៣សម | ខែមីនា ដល់ ខែកក្កដា |
| ៧ | ប៉ោង | គ្រឿង | ៥០ | ខែវិច្ឆិកា ដល់ ខែកក្កដា |
| ៨ | លាន់ | គ្រឿង | ០,៦ម - ១០សម X ១,៥ម | ខែមិថុនា ដល់ ខែធ្នូ |
| ៩ | អួន | វង់ | ២,៥សម X ៣ម X ២៥ម | ខែមីនា ដល់ ខែមិថុនា |
| ១០ | អញ្ចង | វង់ | ៤០សម X ៦ម | ខែមេសា ដល់ ខែកក្កដា |
| ១១ | សំណាញ់ | វង់ | ៣សម X ៧ម | ខែមករា ដល់ ខែមិថុនា |
| ១២ | បបក់ | គ្រឿង | ៥០ | ខែកុម្ភៈ ដល់ ខែមិថុនា |
| ១៣ | ស្ន សម | គ្រឿង | ០,៨ម | ខែមិថុនា ដល់ ខែឧសភា |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ (គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន HYNOTA | ២០០ - ៣០០ | ៥០០ - ១តោន | ៦,៥ ដល់ ១៨ |
| កាណូតម៉ាស៊ីន HONDA , HYUNDIA | ១០ - ២០ | ៥០០ - ១តោន | ៦,៥ ដល់ ១៨ |
| ទូកអុំ ឬទូកចែវ | ៣០ - ៥០ | ១០០ | |

នៅរដូវប្រាំង ជាញឹកញាប់អ្នកខាងក្រៅ ធ្វើដំណើរមកនេសាទ កន្លែងសហគមន៍នេសាទ ដោយមធ្យោបាយផ្សេងៗ ដែលចង្អុលបង្ហាញក្នុងតារាងខាងក្រោម៖

| មធ្យោបាយធ្វើដំណើរ | ចំនួន(គ្រឿង) | ចំណុះ(គក) | ផ្សេងៗ |
|---|---|---|---|
| គោយន្ត | ៣០ | ១០០០ | |
| រទេះក្របី | ៥០ | ៥០០ | |
| ម៉ូតូ | ១០០ | ១០០ | |

## គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគក្រ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ៣,៥០០ | ៥,៥០០ | ៩,០០០ |
| ក្តាម ខ្យង ខ្ចៅ និងលៀស | ២៥០ | ៣៥០ | ៦០០ |
| អន្ទង់ | ៣៥០ | ៤៥០ | ៨០០ |
| សរុប | ៤,១០០ | ៦,៣០០ | ១០,៤០០ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទព្រះគន្លង មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ប្រកបដោយសមធម៌ និងនិរន្តរភាព ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណីឬសហគមន៍ធ្វើនេសាទ ទំនាបលិចទឹកក្នុងរដូវទឹកជំនន់ ព្រៃលិចទឹក និងកន្លែងអន្លង់អភិរក្ស។
- ចូលរួមគ្រប់គ្រងធនធានជលផល ប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋប្រកបដោយសមធម៌ ដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាព សមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះ ដោយមានការចូលរួម
- ដើម្បីឲ្យប្រជាពលរដ្ឋ បានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

**គោលបំណង**

ផែនការប្រើប្រាស់ឧបករណ៍នេសាទ នៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយបានគិតគូរអំពីប្រភេទឧបករណ៍ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ រដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងដែននេសាទ ដោយធ្វើយ៉ាងណា មិនឲ្យការធ្វើនេសាទ លើសពីតម្រូវការធនធានជលផលដែលមានក្នុងកន្លែងសហគមន៍នេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទព្រះគន្លងនៅក្នុងកន្លែងនេសាទត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងព្រយុង | ម៉ែត្រ | ៤៥ម x១,៥ម x០,០៣៥ម | ពីខែ ០២ ដល់ ខែ ០៤ |
| ២ | សន្ទូចបបក់ | ផ្លែ | ១ ផ្លែ | ខែ ០១ ដល់ ខែ ០១ |
| ៣ | សន្ទូចរនង | ផ្លែ | ៥០០ | ខែ ០៨ ដល់ ខែ ១២ |
| ៤ | លបព្រៀង | លប | ៣០ | ខែ ១១ ដល់ ខែ ១២ |
| ៥ | ដាក់ទ្បើ | ទ្បើ | ១០០ | ខែ ១០ ដល់ ខែ ០២ |
| ៦ | ដាក់លាន់ | លាន់ | ៦៥ | ខែ ០៨ ដល់ ខែ ១២ |
| ៧ | ជុច | ជុច | ១០០ | ខែ ០១ ដល់ ខែ ០១ |
| ៨ | សំណាញ់ | សំណាញ់ | ១ វង់ | ខែ ០១ ដល់ ខែ ០៤ |

| ឈ្មោះកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឲ្យប្រើកន្លែងនេសាទសហគមន៍ | | | |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | ផ្សេងៗ |
| បឹងទទឹងថ្ងៃ | សីហា ដល់ មករា | មង | ក្រឡា=៣-៧សម<br>សំរុង=១-២ម | ១០ដៃ/៥នាក់ | ២ដៃ/នាក់ |
| បឹងអាត្រាវ | | សន្ទូច | ផ្លែលេខ១២-១៣ | ៦០០ផ្លែ/៦នាក់ | ១០០ផ្លែ/នាក់ |
| បឹងអាកំបុត | | ប៉ោង | | ២៨០គ្រឿង/៧នាក់ | ៤០គ្រឿង/នាក់ |

| | | | | | |
|---|---|---|---|---|---|
| បឹងកក់ | | ទ្រូអន្ទង | មាត់= ០-២ម<br>ប្រវែង= ០,៤ម | | |
| បឹងក្រពើសម | | លបលួង | ទំហំ=០,៣មx០,៧ម<br>ចន្លោះត្រៀម=២,៥ម | ៥០គ្រឿង/៥នាក់ | ១០គ្រឿង/នាក់ |
| បឹងក្រពើពួយ | | បបក់ | | ៥បបក់ | ១បបក់/នាក់ |
| បឹងអាខ្វាក់ធំ | | | | | |
| បឹងខ្វែកអាស្តរ | | | | | |
| បឹងអាត្រាព្រួល | | លប់ទល់ | ទំហំ=០,៦មx១,៦ម<br>ចន្លោះត្រៀម=២,៥ម | ៥០គ្រឿង/៥នាក់ | ១០គ្រឿង/នាក់ |
| បឹងមោង | | | | | |
| បឹងប្រវឹក | | មងហ៊ុំ | ក្រឡា= ៤ - ៥សម<br>សំរុង= ១ - ២ម | ២វង់ | ១វង់/នាក់ |
| បឹងព្រលិត | | | | | |
| បឹងរាំងកោង | | | | | |
| បឹងក្រពើគ្រហឹម | | | | | |
| បឹងខ្វែងអាស្តរ | | | | | |
| បឹងអន្លង់រាជ | **មករា ដល់ ធ្នូ** | មង | ក្រឡា= ៣ - ៧សម<br>សំរុង= ១,៥ - ២ម | ៧៥ដៃ/១៥នាក់<br>១ដៃ= ៤០ម | ៥ដៃ/១នាក់ |
| | | សន្ទូច | ផ្លែលេខ១២-១៣ | ៤០០០ផ្លែ/២០នាក់ | ២០០ផ្លែ/នាក់ |
| | | លបទល់ | ទំហំ=០,៦មx១,៦ម<br>ចន្លោះត្រៀម=២,៥ម | ២០០គ្រឿង/១០នាក់ | ២០គ្រឿង/<br>នាក់ |
| | | ឡើ | ទំហំ=០,៥មx០,៧ម<br>ក្រឡា=២សម | ៣០០គ្រឿង/១០នាក់ | ៣០គ្រឿង/<br>នាក់ |
| | | លបលួង | ទំហំ=០,៣មx០,៧ម<br>ចន្លោះត្រៀម=២,៥ម | ៩០០គ្រឿង/៣០នាក់ | ៣០គ្រឿង/<br>នាក់ |
| | | ដុច | | ៥០០គ្រឿង/១០នាក់ | ៥០គ្រឿង/នាក់ |
| បឹងព្រះគន្លង | | ប៉ោង | | ៤០០គ្រឿង/២០នាក់ | ២០គ្រឿង/<br>នាក់ |
| | | លាន់ | ទំហំ=០,៦ម-១០សម<br>ចន្លោះត្រៀម=១,៥ម | ២០០គ្រឿង/៥នាក់ | ៤០គ្រឿង/នាក់ |
| | **មករា ដល់** | អួន | ក្រឡា=៣,៥-៦,៥<br>សម | ៤០ម/២នាក់ | ២០ម/នាក់ |

| | | | | | |
|---|---|---|---|---|---|
| | ធ្នូ | | សំរុង= ២,៥ - ៣ម<br>ប្រវែង= ១៥ - ៣០ម | | |
| | | អញ្ចង | ក្រឡា=២ - ៤សម<br>ប្រវែង= ៦ម | ៤០ម/២នាក់ | ២០ម/នាក់ |
| | | សំណាញ់ | ក្រឡា=២ - ៤សម<br>ប្រវែង= ៦ម | ១០វង់/១០នាក់ | ១វង់/នាក់ |
| | | ទ្រូញឹក | មុខ= ០,៦ម<br>ប្រវែង= ១,២ម | ១២គ្រឿង/២នាក់ | ៦គ្រឿង/នាក់ |
| | | ទ្រូអន្ទង់ | មាត់ = ០,២ម<br>ប្រវែង= ០,៤ម | ២០០គ្រឿង/១០នាក់ | ២០គ្រឿង/នាក់ |
| | | បបក់ | | ១០បបក់ | ១បបក់/នាក់ |
| | | ឈ្នាង | | ១០គ្រឿង | ១គ្រឿង/នាក់ |
| | | អង្រុត | | ១០គ្រឿង | ១គ្រឿង/នាក់ |
| | | ស្នសម | ប្រវែង= ០,៨ម | ៥គ្រឿង | ១គ្រឿង/នាក់ |
| គ្រពាំងអាក្អុត | **សីហា ដល់ មករា** | មង | ក្រឡា= ៣ - ៧សម<br>សំរុង= ១,៥ - ២ម | ៣០០ដៃ/២នាក់<br>១ដៃ= ៤០ម | ១៥០ដៃ/១នាក់ |
| គ្រពាំងជាន់អន្លង់ | | សន្ទូច | ផ្លែលេខ១២-១៣ | ៤០០០ផ្លែ/២០នាក់ | ២០០ផ្លែ/នាក់ |
| គ្រពាំងថ្លុកឆេង | **កុម្ភៈ ដល់ មេសា** | លបលួង | ទំហំ=០,៣មx០,៧ម<br>ចន្លោះគ្រៀម=២,៥ម | ៣០គ្រឿង/២០នាក់ | ១៥គ្រឿង/នាក់ |
| គ្រពាំងថ្លុកតាសែង | | លាន | ទំហំ=០,៦ម-១០សម<br>ចន្លោះគ្រៀម=១,៥ម | ៥០គ្រឿង/២នាក់ | ២៥គ្រឿង/នាក់ |
| គ្រពាំងថ្លុកតាកែវ | | ដុច | | ៦០គ្រឿង/២នាក់ | ២គ្រឿង/នាក់ |
| គ្រពាំងថ្លុកជឿន | **មេសា ដល់ ឧសភា** | មងរ៉ៃ | ក្រឡា= ៣ - ៥សម<br>សំរុង= ៣ម<br>ប្រវែង= ២៥ម | ២៥ម/១នាក់ | ២៥ម/នាក់ |
| គ្រពាំងថ្លុកតារ៉ែន | | | | | |

**គ.២. ផែនការកែលំអដែននេសាទ**

ផែនការកែលំអដែននេសាទ គឺជាការងារមួយ ដែលត្រូវទាមទារមានការគាំទ្របច្ចេកទេស ថវិកា និងការប្រើប្រាស់ពេលវេលា ធ្វើការសិក្សាមួយច្បាស់លាស់ ពីព្រោះថាការកែលំអដែននេសាទសហគមន៍នេះវាពាក់ព័ន្ធជាមួយត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទនៅក្នុងដែននេសាទនោះ។ ដូចនេះផងដែរ ក្នុងកិច្ចប្រជុំរវាងគណៈកម្មការសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន និងក្រុមសម្របសម្រួលរដ្ឋបាលជលផលថ្នាក់កណ្តាល បានពិនិត្យឃើញថាដែននេសាទនៅក្នុងសហគមន៍នេសាទព្រះគន្លង មានសភាពប្រែប្រួលខ្លះ ដែលបណ្តាលមកពីកត្តាមនុស្ស និងធម្មជាតិ ដូចជាព្រែកដែលធ្វើចរាចរទទួលនូវការរីងរាក់ដែលបណ្តាលមកពីការដាក់ក្នុងព្រែក និងជាសៀវព្រោះដោយសារការកាប់ទន្រ្ទាញព្រៃលិចទឹកនៅតាមមាត់ព្រែក ។

ផែនការកែលំអដែននេសាទ ក្នុងគោលបំណង៖

- បង្កើនផលត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ។
- ធ្វើឱ្យសំបូរព្រៃលិចទឹកឲ្យនៅក្នុងដែននេសាទសហគមន៍។

ផែនការកែលំអដែននេសាទ នឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ ហត | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ខាងត្បូងបឹងអន្លុងរាជ | ៥១.២៦ | ៥ហត | ធ្វើការសិក្សា | ខែតុលា ២០១៨ | ខែធ្នូ២០១៨ |
| | | | ស្តារបឹង | ខែមករា ២០១៩ | ខែធ្នូ ២០១៩ |
| ជុំវិញបឹងព្រះគន្លង | ៧៩.៥១ | ៦ហត | | | |

## គ.៣. ផែនការរៀបចំកន្លែងអភិរក្ស

សហគមន៍នេសាទព្រះគន្លង បានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សចំនួន០៤កន្លែង គឺអន្លង់កោះម្នាង និងទួលអន្លង់កោះរាជ បឹងអាខ្វាក់ធំ ព្រៃអាខ្វាក់ ដែលជាកន្លែងមានសក្តានុពល សម្រាប់អភិរក្សត្រីមេពូជ។ ដូចនេះផងដែរ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទព្រះគន្លង ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ហើយកន្លែងអភិរក្សត្រីមេពូជទាំងពីរ នេះបង្កើតឡើងក្នុងគោលបំណង៖

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សាការពារព្រៃលិចទឹក ដែលជាជម្រក និងប្រភពចំណី របស់ត្រី និងសត្វ
- ផ្តល់ចំណេះដឹង ដល់ប្រជាពលរដ្ឋ ឱ្យចេះស្រឡាញ់ថែរក្សា ការពារធនធានធម្មជាតិ
- ចូលរួមថែរក្សាការពារធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

តាមការចុះអង្កេត ពិនិត្យ និងពិភាក្សា លើលក្ខណៈវិនិច្ឆ័យជាមួយគណៈកម្មការ និងសមាជិកសហគមន៍នេសាទ បានបញ្ជាក់ថា៖ គឺអន្លង់កោះម្នាង និងទួលអន្លង់កោះរាជ បឹងអាខ្វាក់ធំ ព្រៃអាខ្វាក់ គឺជាកន្លែងសំខាន់បំផុតសម្រាប់ធ្វើការអភិរក្ស ដែលសមាជិកសហគមន៍នេសាទព្រះគន្លង មានសុច្ឆន្ទៈចង់ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល ដើម្បីធានានូវប្រសិទ្ធភាព នៃការគ្រប់គ្រងធនធានជលផល និងជាប្រយោជន៍សម្រាប់តម្រូវការរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។

កន្លែងអភិរក្សត្រីមេពូជ ជាកត្តាចាំបាច់ ដែលត្រូវរៀបចំកំណត់ព្រំប្រទល់ បោះបង្គោលស៊ីម៉ងព្រំប្រទល់ ធ្វើប៉ាណូផ្សព្វផ្សាយ ក្តារខៀនព័ត៌មាន បិទផ្សាយបទបញ្ញត្តិផ្សេងៗ សាងសង់រោងយាមសម្រាប់ក្រុមល្បាតបំពេញការងារមធ្យោបាយ និងសម្ភារៈផ្សេងៗទៀត។

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ទីតាំង | ទំហំ ហត | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| អន្លង់កោះម្នាង | ២ | • ប្រភេទត្រីសំខាន់<br>• ប្រភេទសត្វស្លាប<br>• ប្រភេទពពួកល្មូន<br>• ព្រៃលិចទឹក | • បោះបង្គោលស៊ីម៉ង់បន្ថែមចំនួន ៧ ដើម<br>• ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>• ចុះល្បាតជាប្រចាំ | ២០១៧ | ២០១៨ |
| ទួលអន្លង់កោះរាជ | ២,៥ | • ប្រភេទត្រីសំខាន់ | • សិក្សាពីកន្លែងអភិរក្ស | ២០១៨ | ២០១៩ |

| | | | | | |
|---|---|---|---|---|---|
| | | • ប្រភេទសត្វស្លាប<br>• ប្រភេទពពួកល្មូន<br>• ព្រៃលិចទឹក | • បោះបង្គោលចំនួន ៧ ដើម<br>• ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>• ធ្វើប៉ាណូផ្សព្វផ្សាយ<br>• សង់រោងយាម<br>• ចុះល្បាតជាប្រចាំ | | |
| បឹងអាខ្លាក់ធំ | | • ប្រភេទត្រីសំខាន់<br>• ប្រភេទសត្វស្លាប<br>• ប្រភេទពពួកល្មូន<br>• ព្រៃលិចទឹក | • សិក្សាពីកន្លែងអភិរក្ស<br>• បោះបង្គោលចំនួន ៧ ដើម<br>• ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>• ធ្វើប៉ាណូផ្សព្វផ្សាយ<br>• សង់រោងយាម<br>• ចុះល្បាតជាប្រចាំ | ២០១៨ | ២០១៩ |
| ព្រៃបឹងអាខ្លាក់ | | • ប្រភេទត្រីសំខាន់<br>• ប្រភេទសត្វស្លាប<br>• ប្រភេទពពួកល្មូន<br>• ព្រៃលិចទឹក | • សិក្សាពីកន្លែងអភិរក្ស<br>• បោះបង្គោលចំនួន ៧ ដើម<br>• ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>• ធ្វើប៉ាណូផ្សព្វផ្សាយ<br>• សង់រោងយាម<br>• ចុះល្បាតជាប្រចាំ | ២០១៨ | ២០១៩ |

### គ.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក

នាទីព្រៃលិចទឹក បានគ្របដណ្តប់លើដែននេសាទសហគមន៍ព្រះគន្លង ដែលបានផ្តល់នូវសក្តានុពល និងសារៈប្រយោជន៍ជាច្រើន ដល់ប្រភេទត្រី សត្វល្មូន ប្រភេទសត្វ និងវារីសត្វផ្សេងៗទៀត សម្រាប់ជាជម្រករស់នៅ បង្កកំណើត និងជាប្រភពចំណីផងដែរ។ ដូចនេះផែនការគ្រប់គ្រងព្រៃលិចទឹកក្នុងគោលបំណង៖

- ថែរក្សា ការពារព្រៃលិចទឹកឱ្យនៅគង់វង្សយូរអង្វែងដល់ក្មេងជំនាន់ក្រោយ។
- ទុកជាជម្រកត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ទប់ស្កាត់ការហូរច្រោះទឹករលក និងជារបាំងខ្យល់។
- បង្កើនទិន្នផលត្រី និងពពួកសត្វមានជីវិតគ្រប់ប្រភេទឲ្យសំបូរឡើងវិញ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍។

គណៈកម្មការ និងសមាជិកសហគមន៍នេសាទ បានកំណត់និងបែងចែកនាទីព្រៃលិចទឹកមានកន្លែងអភិរក្ស និងកន្លែងប្រើប្រាស់រំលោះដោយផ្អែកតាមផែនទីសហគមន៍នេសាទ។កន្លែងប្រើប្រាស់ព្រៃលិចទឹក ត្រូវអប់រំណែនាំដល់ប្រជាពលរដ្ឋឲ្យចេះកាប់រំលោះមែក ដែលធ្វើយ៉ាងណាមិនឱ្យងាប់ ដើម្បីយកមកប្រើប្រាស់ជាអុសចំអិនអាហារ ការកាប់រំលោះនេះ ធ្វើជាលក្ខណៈវិលជុំជារៀងរាល់បីឆ្នាំម្តង ដើម្បីទុកឱ្យព្រៃមានលទ្ធភាពអាចដុះលូតលាស់ឡើងវិញបាន។

ដោយសារការយល់ដឹង ពីសារៈសំខាន់នៃនាទីព្រៃលិចទឹក ប្រជាពលរដ្ឋមានការចូលរួមចំណែក យ៉ាងសកម្ម ក្នុងការគ្រប់គ្រងធនធានជលផលឱ្យប្រសើរឡើង ។

ខាងក្រោមនេះជាផែនការគ្រប់គ្រងនាទីព្រៃលិចទឹកក្នុងសហគមន៍មានដូចជា៖

| ឈ្មោះទីតាំង | ទំហំហត | កូនឈើដែលត្រូវការពារ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| ដាំព្រៃលិចពទ្ធ័ជុំវិញបឹងអាខ្វាក់ | ២០ | រាំង ផ្ទោល ត្នូរ និងច្រកែង | • ផ្សព្វផ្សាយពីផលប្រយោជន៍នៃការគ្រប់គ្រងព្រៃលិចទឹក | ១៨/១/១៧ | ២២/១/១៨ |
| | | | • រៀបចំកូនឈើ | ២៧/៥/១៧ | ០៥/៦/១៨ |
| | | | • ដាំកូនឈើ និងដាក់ស្លាកសញ្ញា | ១០/៦/១៧ | ១៣/៦/១៨ |
| | | | • ថែរក្សា និងការពារ | ១៣/៦/១៧ | ៣០/៩/១៨ |
| ថែរក្សនិងការពារព្រៃលិចទឹក | | ព្រៃលិចទឹកគ្រប់ប្រភេទ | • ផ្សព្វផ្សាយផែនការ គ្រប់គ្រងព្រៃ | ៣/១/១៩ | ៥/១/១៩ |
| | | | • ដាក់ស្លាកសញ្ញាការពារ | ៥/៣/១៩ | ១០/៣/១៩ |
| | | | • ត្រួតពិនិត្យ និងការពារ | ជាប្រចាំ | |

## គ.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ក្រៅពីនេសាទត្រី ការចិញ្ចឹមត្រីជាមុខរបរចំបងរបស់ប្រជានេសាទ នៅក្នុងសហគន៍ព្រះគន្លង ជាទូទៅប្រជាពលរដ្ឋក្នុងសហគមន៍នេសាទនេះ ច្រើនចិញ្ចឹមត្រីនៅតាមស៊ង និងបែរ ដែលការចិញ្ចឹមត្រីមានដូចជា៖ ត្រីរ៉ស់ ត្រីប្រា និងត្រីអណ្តែង។ល។ ការចិញ្ចឹមត្រីជាទម្លាប់របស់ប្រជាពលរដ្ឋ ជាយូរឆ្នាំមកហើយ ដោយអ្នកខ្លះចាប់បានពូជត្រីពីធម្មជាតិ អ្នកខ្លះទៀតចិញ្ចឹមដូចលក្ខណៈប្រស់ ឬចិញ្ចឹមបំប៉នឲ្យមានទំហំសមស្របសម្រាប់តម្រូវការទីផ្សារ។

ការចិញ្ចឹមត្រី ជាទិសដៅដ៏សំខាន់របស់វិស័យជលផល ក្នុងការបង្កើនត្រីសាច់ សម្រាប់ហូបរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចជាតិឱ្យមានការរីកចំរើន។ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសលេខ ៣២៥ ប្រក កសក ស្តីពី ការគ្រប់គ្រង ការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោរ ដែលស្របនឹងតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋាន។ ដូចនេះផងដែរ សហគមន៍នេសាទព្រះគន្លង បានផ្តោតសំខាន់លើការចិញ្ចឹមត្រីតាមបែរ ដែលការចិញ្ចឹមត្រីមានដូចជា៖ ត្រីរ៉ស់ និងត្រីអណ្តែង ពីព្រោះសហគមន៍នេះស្ថិតក្បែរបឹងទន្លេសាបដោយមានព្រែកតភ្ជាប់ជាមួយបឹងទន្លេសាប។

ការអភិវឌ្ឍន៍វារីវប្បកម្មរបស់សហគមន៍នេសាទព្រះគន្លងក្នុងគោលបំណង ៖

- បង្កើនត្រីសាច់សម្រាប់ហូប របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

ឆ្លើយតបនឹងទៅនឹងការពង្រីកការអភិវឌ្ឍន៍វារីវប្បកម្ម គណៈកម្មការ និងសមាជិកសហគមន៍នេសាទបានរៀបចំផែនការអភិវឌ្ឍន៍ការចិញ្ចឹមត្រីដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ(ក្បាល) | ខែ/ឆ្នាំចាប់ផ្តើម | ខែ/ឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីតាមបច្ចេកទេសជាលក្ខណៈគ្រួសារក្នុងបែរ | • វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>• ធ្វើបែរឬស៊ីចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ៣០បែរ ៣មx២ម | - ដំរី<br>- ប្រា<br>- អណ្តែង | ១,០០០ក្បាល ក្នុង១បែរ | ១០/៩/១៧ | ៣០/៩/១៧ |

| | | | | | | |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីតាមបច្ចេកទេសជាលក្ខណៈគ្រួសារក្នុងស្រះ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• វគ្គបណ្តុះបណ្តាល<br>• ធ្វើប៉ែចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ១៥ ប៉ែ ទំហំ ៥ម x ២,៥ ម ត្រីអណ្តែង | | ៤,០០០/គ្រួសារ | ១២/៧/១៩ | ២៥/៧/១៩ |

## គ.៦. ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ដោយឡែក គណៈកម្មការសហគមន៍ បានដើរតួនាទីសំខាន់ ក្នុងការស្វែងរកប្រាក់ចំណូលពីប្រភពផ្សេងៗ ដូចជា៖ ភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរសជនក្រុមប្រឹក្សាឃុំ។

ដូចនេះ ផែនការស្វែងរកថវិការសម្រាប់ទ្រង់សហគមន៍នេះ មានក្នុងតារាងខាងក្រោះ

| ប្រភេទចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូល (រៀល) |
|---|---|---|---|---|
| ភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍ | - ផ្សព្វផ្សាយបន្ថែមពីលក្ខន្តិកៈ បទផ្ទៃក្នុង<br>- ប្រមូលវិភាគទានពីសមាជិកសហគមន៍ | ២០១៧ | ២០១៩ | ១៥៥.០០០ |
| ភាគទានពីអ្នកនេសាទខាងក្រៅ | ប្រមូលវិភាគទានពីសមាជិកសហគមន៍ | ២០១៧ | ២០១៩ | ៤៥០.០០០ |
| ជំនួយសប្បុរសជន អង្គការដៃគូ និងក្រុមប្រឹក្សាឃុំ | ទំនាក់ទំនងស្វែងរក<br>- ជំនួយសប្បុរសជន<br>- អង្គការដៃគូ<br>- ដាក់សំណើសុំថវិកា | ២០១៧ | ២០១៩ | ៧.០០០.០០០ |

## គ.៧. ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ

### គោលបំណង

- ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរ និងមានដើមទុនសំរាប់បង្កើនប្រាក់ចំណូល
- កាត់បន្ថយអត្រាការប្រាក់ខ្ពស់ និងខ្ចីប្រាក់ពីឈ្មួញ
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង។

| ប្រភេទមុខរបរ | សកម្មភាព | ចាប់ផ្តើម | បញ្ចប់ |
|---|---|---|---|
| បង្កើតក្រុមសន្សំប្រាក់ ១ក្រុម (១៥ គ្រួសារ នឹងឧបត្ថម្ភដោយអង្គការ FAO | • ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហគមន៍<br>• ការរៀបចំក្រុមសន្សំ<br>• ជ្រើសរើសប្រធាន អនុប្រធាន និងហិរញ្ញឹក<br>• បង្កើតគោលការណ៍ និងបទបញ្ញាផ្ទៃក្នុង ផ្តល់ទុន<br>• បណ្តុះបណ្តាលពីការរៀបចំឯកសារ និងថវិកា ត្រួតពិនិត្យតាមដាន | ៧/១២/១៧ | ២០/១២/១៩ |

### គ.៧.១.ក្រុមសន្សំ

| ប្រភេទមុខរបរ | សកម្មភាព | ចាប់ផ្តើម | បញ្ចប់ |
|---|---|---|---|
| បង្កើតក្រុមសន្សំប្រាក់ បានចំនួន ២ក្រុម ១ក្រុម = ៣០នាក់ | • ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហគមន៍<br>• ការរៀបចំក្រុមសន្សំ ការផ្តល់ទុន<br>• បោះឆ្នោតជ្រើសរើសប្រធាន អនុលេខា និងហិរញ្ញិក<br>• បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• បណ្តុះបណ្តាលក្រុមលើឯកសារផ្សេងៗ និងថវិកា<br>• ប្រជុំក្រុមសន្សំប្រាក់ប្រចាំខែត្រួតពិនិត្យតាមដាន | ៧/២/១៩ | ២០/២/១៩ |

### គ.៨. ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ជាទូទៅ បេក្ខជនដែលឈរឈ្មោះជាគណៈកម្មការសហគមន៍នេសាទ គួរត្រូវបានបញ្ជាក់ពីគុណភាព និងចំណេះដឹងដូចជា៖ ចេះអាន សរសេរ អាកប្បកិរិយាសមរម្យ ដោយឯកភាពពីសមាជិកសហគមន៍ ហើយការរៀបចំបោះឆ្នោតជ្រើសរើសជាគណៈកម្មការបានប្រើនីតិវិធីដែលស្របតាមគោលការណ៍ណែនាំសហគមន៍នេសាទ ដែលបានអនុម័តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ជាក់ស្តែងគណៈកម្មការសហគមន៍នេសាទនេះ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយត្រឹមត្រូវ និងយុត្តិធម៌ដែលមានសំឡេងគាំទ្រច្រើនជាងគេ ហើយជាញឹកញាប់សមាសភាពគណៈកម្មការសហគមន៍នេសាទ មានកំរិតលើការយល់ដឹងពីលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ជំនាញសម្របសម្រួល ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងការៀបផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ។ ដូចនេះ ផែនការបណ្តុះបណ្តាលដល់សមាសភាពគណៈកម្មការសហគមន៍នេសាទនឹងត្រូវបានរៀបចំក្នុងគោលបំណង យល់ពីតួនាទី ភារកិច្ចរបស់ពួកគាត់ បង្កើនសាមគ្គីភាព និងការទំនាក់ទំនងល្អជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ គណៈកម្មការសហគមន៍នេសាទនឹងអាចអនុវត្តសកម្មភាពក្នុងការងារ។

| ផែនការ | ប្រធានបទ/ជំនាញ | ក្រុមគោលដៅ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ការពង្រឹងសម្ថតភាព | កំណត់ហេតុនិងរបាយការណ៍ | សមាជិកនិងគណៈកម្មការ | | PIU និង FAO |
| | របៀបសរសេរលិខិតរដ្ឋបាល | សមាជិកនិងគណៈកម្មការ | | PIU និង FAO |
| | រៀបចំទុកដាក់ឯកសារ | សមាជិកនិងគណៈកម្មការ | | PIU និង FAO |
| | របៀបកត់ត្រាប្រចាំថ្ងៃ | សមាជិកនិងគណៈកម្មការ | | PIU និង FAO |
| ការងារគ្រប់គ្រង | ការគ្រប់គ្រងថវិកា | សមាជិកនិងគណៈកម្មការ | | PIU និង FAO |
| | ការដោះស្រាយទំនាស់ | សមាជិកនិងគណៈកម្មការ | | PIU និង FAO |
| | សរសេរ សំណើសុំថវិកា | សមាជិកនិងគណៈកម្មការ | | PIU និង FAO |
| | រៀបចំបណ្តាញសហគមន៍ | សមាជិកនិងគណៈកម្មការ | | PIU និង FAO |
| | ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | សមាជិកនិងគណៈកម្មការ | | PIU និង FAO |
| បណ្តុះបណ្តាល | បណ្តុះ និងដាំព្រៃលិចទឹក | សមាជិកនិងគណៈកម្មការ | | PIU និង FAO |
| បច្ចេកទេស | ចិញ្ចឹមត្រី មាន់ ទា ជ្រូក........ | សមាជិកនិងគណៈកម្មការ | | PIU និង FAO |
| | បណ្តុះផ្សិត | សមាជិកនិងគណៈកម្មការ | | PIU និង FAO |
| | ផលិតជីកំប៉ុស្តិ៍ និង EM | សមាជិកនិងគណៈកម្មការ | | PIU និង FAO |

## គ.៩. ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និង លិខិតបទដ្ឋានពាក់ព័ន្ធ

ពេលបច្ចុប្បន្ន ធនធានជលផលក្នុងសហគមន៍កំពុងទទួលរងនូវការគំរាមកំហែងពីអ្នកខាងក្នុងនិងខាងក្រៅ ដោយការកាប់រានព្រៃលិចទឹក និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់។ ដូចនេះ ដើម្បីធានាការប្រើប្រាស់ធនធានជលផល ពេលអនាគត និងបានយូរអង្វែងនោះ តម្រូវធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពី ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីឲ្យមានការយល់ដឹងគ្រប់គ្រាន់ និងចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព។ ការផ្សព្វផ្សាយច្បាប់ស្តីពី ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងគោលបំណង៖

- បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍
- កាត់បន្ថយសកម្មភាពបទល្មើសនេសាទក្នុងសហគមន៍ផែនការសកម្មភាពមានដូចខាងក្រោម៖

| ប្រធានបទ | ក្រុមគោលដៅ | ពេលវេលា(១ឆ្នាំម្តង) | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| លក្ខខន្តិកៈ និង បទបញ្ជាផ្ទៃក្នុង | សមាជិកនិងគណៈកម្មការ | ខែកុម្ភៈ និង ខែតុលា | PIU និង FAO |
| សារៈប្រយោជន៍នៃធនធានជលផល | សមាជិកនិងគណៈកម្មការ | ខែមេសា | PIU និង FAO |
| ផែនទីកំណត់ព្រំប្រទល់កន្លែងនេសាទ | សមាជិកនិងគណៈកម្មការ | ខែតុលា និង ខែធ្នូ | PIU និង FAO |
| ផែនការគ្រប់គ្រងកន្លែងនេសាទ | សមាជិកនិងគណៈកម្មការ | ខែមករា | PIU និង FAO |
| ច្បាប់ជលផលទាក់ទងនិងសហគមន៍ | សមាជិកនិងគណៈកម្មការ | ខែឧសភា និង ខែកញ្ញា | PIU និង FAO |
| សារៈប្រយោជន៍នៃព្រៃលិចទឹក | សមាជិកនិងគណៈកម្មការ | ខែមករា | PIU និង FAO |
| ការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ | សមាជិកនិងគណៈកម្មការ | ខែកុម្ភៈ និង ខែមិថុនា | PIU និង FAO |

## គ.១០.ផែនការសង់ស្នាក់ការ និងផ្លូវសហគមន៍នេសាទ

ពេលបច្ចុប្បន្ន សហគមន៍នេសាទព្រះគន្លង ពុំទាន់មានស្នាក់ការសម្រាប់គណៈកម្មការសហគមន៍នេសាទធ្វើការនៅឡើយទេ ដែលអាចបង្កការលំបាកក្នុងពេលបំពេញការងារគណៈកម្មការសហគមន៍នេសាទ ក៏ដូចជាការងារទំនាក់ទំនងជាមួយក្រុមការងារផ្សេងៗ ឬភ្ញៀវទេសចរណ៍ជាដើម ។ ដូច្នេះ គណៈកម្មការសហគមន៍នេសាទនេះមានផែនការសាងសង់ស្នាក់ការសហគមន៍មានដូចខាងក្រោម៖

| ប្រភេទសកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | តម្លៃប៉ាន់ ស្មាន(រៀល) | ប្រភពទុន |
|---|---|---|---|---|
| ផែនការសាងសង់ស្នាក់ការ | ២០១៧ | ២០២២ | ២៨.០០០.០០០ | រាជរដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន |
| ផែនការគ្រប់គ្រងជួសជុលផ្លូវ | ២០១៧ | ២០២២ | ២៨.០០០.០០០ | |
| តុ កៅអី និងទូឯកសារ | ២០២២ | ២០២២ | ២.០០០.០០០ | |
| សរុប | ៣០.០០០.០០០ | | | |

## គ.១១. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ដោយឡែក គណៈកម្មការសហគមន៍ បានដើរតួនាទសំខាន់ ក្នុងការស្វែងរកប្រាក់ចំណូល និងចំណាយពីប្រភព ផ្សេងៗដូចជា ភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរសជន ចំណូលពីក្រុមសន្សំប្រាក់ ១ក្រុម។ ដូចនេះ ផែនការស្វែងរកថវិការសម្រាប់ទ្រង់សហគមន៍មានក្នុងតារាងខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ចំណូលសរុបរៀល |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះប្រមូលប្រាក់សមាជិកភាព | ២០១៧ | ២០២២ | ១.៥៧៧.៥០០ |
| ភាគទានប្រចាំឆ្នាំ | ចុះប្រមូលប្រាក់ ភាគទានប្រចាំឆ្នាំ | ២០១៧ | ២០២២ | ១.០០០.០០០ |
| ភាគទានពីអ្នកខាងក្រៅឬអ្នកមិនមែនជាសមាជិក | ប្រមូលប្រាក់បដិភាគពីអ្នកនេសាទខាងក្រៅ | ២០១៧ | ២០២២ | ២៥០.០០០ |
| | ប្រមូលប្រាក់អ្នកមិនមែនជាសមាជិក | ២០១៧ | ២០២២ | ៥០០,០០០ |
| ភាគទានពីក្រុមសន្សំ | ប្រមូលប្រាក់បដិភាគពីក្រុមសន្សំ | ២០១៧ | ២០២២ | ២០០.០០០ |
| សរសេរគម្រោងស្នើសុំៈ<br>-បដិភាគពីរាជរដ្ឋាភិបាល<br>-អំណោយពីសប្បុរសជន<br>- អង្គការដៃគូ | -បញ្ចូលផែនការទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>-សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | ២០១៧ | ២០២២ | ១.០០០.០០០ |
| **សរុប** | | | | **៤,៥២៧,៥០០** |

**គ.១២. ផែនការពង្រឹងបណ្តាញសហគមន៍នេសាទ និងចូលរួមប្រជុំផ្សេងៗ**

សហគមន៍នេសាទ មានសិទ្ធិរៀបចំបណ្តាញសហគមន៍នេសាទ ក្នុងគោលបំណង ចែករំលែកព័ត៌មាន បទពិសោធន៍ និងមេរៀន ដែលបានរៀនសូត្រ ក្នុងការគ្រប់គ្រង និងការអភិវឌ្ឍន៍សហគមន៍នេសាទ ក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ជាផលប្រយោជន៍រួមរបស់សហគមន៍នេសាទទាំងអស់។ បណ្តាញសហគមន៍នេសាទ គឺជាការចងសម្ព័ន្ធរួមគ្នារវាងសហគមន៍នេសាទនិងសហគមន៍នេសាទ ដែលសម្របសម្រួលដោយសមាជិក ដែលបានជ្រើសរើសឆ្លងកាត់ការទទួលខុសត្រូវពីក្រុមសហគមន៍នេសាទ។ បណ្តាញសហគមន៍នេសាទ មានថ្នាក់ស្រុក ខេត្ត តំបន់ និងថ្នាក់ជាតិ។

បណ្តាញសហគមន៍នេសាទនីមួយៗនឹងត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតជ្រើសរើសចេញពីប្រធានគណៈកម្មការសហគមន៍នេសាទពាក់ព័ន្ធដោយសេរីត្រឹមត្រូវ និងយុត្តិធម៌ ។ បណ្តាញសហគមន៍នេសាទនឹងមានតួនាទីជួយសម្របសម្រួល និងបានការគាំទ្រពីរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ។

បណ្តាញសហគមន៍នេសាទក្នុងគោលបំណងៈ

- រំលែកព័ត៌មាន បទពិសោធន៍ ក្នុងការគ្រប់គ្រង និងការអភិវឌ្ឍន៍សហគមន៍នេសាទ
- បង្កើនការទំនាក់ទំនងល្អជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ។

| ល.រ | សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ១ | ប្រជុំបណ្តាញសហគមន៍នេសាទថ្នាក់ស្រុក | ៤ដង/១ឆ្នាំ | ២០១៧ | ២០២២ |
| ២ | ប្រជុំបណ្តាញសហគមន៍នេសាទថ្នាក់ខេត្ត | ១ដង/១ឆ្នាំ | ២០១៧ | ២០២២ |
| ៣ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | ២០១៧ | ២០២២ |
| ៤ | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | ២០១៧ | ២០២២ |

### ឃ.យុទ្ធសាស្រ្ត

នៅក្នុងសហគមន៍នេសាទព្រះគន្លង ត្រូវបានរៀបចំយុទ្ធសាស្រ្តមួយចំនួន ដើម្បីឲ្យការអនុវត្តផែនការទទួលបានជោគជ័យ ហើយយុទ្ធសាស្រ្តទាំងនោះមានដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការរួមមាន៖ សមាជិកគណៈ កម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អជាពិសេសអំពីបញ្ហានេសាទ។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារ ព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម។
- រៀបចំយុទ្ធសាស្រ្តទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោងនិងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រនិងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ។
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់។
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ។
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ។
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍។
- ពង្រឹងសមត្ថភាពបច្ចេកទេសនិងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ។
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ។
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

| ប្រភេទផែនការ/សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (រៀល) | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ |
| --- | --- | --- | --- | --- | --- |
| ១.ផែនការប្រើប្រាស់ឧបណ៍នេសាទ | • កាត់បន្ថយទំនាស់នេសាទក្នុងកន្លែងនេសាទ<br>• កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់<br>• សហគមន៍នឹងអនុវត្តន៍ប្រកាសស្ដីពីការប្រើប្រាស់ឧបករណ៍ | | | | |
| ១.១.ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារក្នុង១ឆ្នាំ/៣ដង | សមាជិកនឹងយល់ដឹងពីការការប្រើប្រាស់ឧបករណ៍នេសាទ | ៧០០.០០០ | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០១៧ | ២០២២ |
| ១.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | អ្នកពាក់ពន្ធ នឹងចូលរួមផ្សព្វផ្សាយបន្តដល់សហគមន៍ដទៃ | | | | |
| ១.៣.ត្រួតពិនិត្យ និងតាមដាន | គណៈកម្មការនិងសមាជិកចូលរួមឃ្លាំមើល និងរាយការណ៍ | | | | |
| ២.ផែនការកែលំអដែននេសាទ | - បង្កើនផលត្រី វារីសត្វគ្រប់ប្រភេទ និងព្រៃលិចទឹក<br>- ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ<br>- ទាក់ទាញភ្ញៀវទេសចរណ៍ និងផ្ដល់ការងារដល់អ្នកខាងក្នុង | | | | |
| ២.១.លើកទំនប់ស្ទាក់ទឹក២កន្លែង | •ផ្សព្វផ្សាយដល់អ្នកពាកព័ន្ធទាំងអស់<br>•ធ្វើការសិក្សាលើទំហំដែលត្រូវស្ដារ<br>•ការស្ដារ | ២៨.០០០.០០០ | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០១៧ | ២០២២ |
| ៣.ការរៀបចំកន្លែងអភិរក្ស | •ត្រីមេពូជ សត្វស្លាប និងសត្វល្មូនសំខាន់ៗ ត្រូវបានធ្វើការអភិរក្ស<br>•ប្រភេទព្រៃលិចទឹកនឹងត្រូវបានការពារ<br>•ប្រជាជនយល់ដឹងពីសារៈប្រយោជន៍ការអភិរក្ស និងចូលរួមថែរក្សា | | | | |
| ៣.១ បោះបង្គោលស៊ីម៉ង់កន្លែងអភិរក្ស | •ចំនួន ៦ បង្គោលនឹងបានបោះនៅកន្លែងអភិរក្ស<br>•មានផែនទីសំគាល់កន្លែងអភិរក្ស | ៥.០០០.០០០ | FAO<br>រាជរដ្ឋាភិបាល | ២០១៧ | ២០២២ |
| ៣.២ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីកន្លែងអភិរក្ស | •ប្រជាជនមានការយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស | | រាជរដ្ឋាភិបាល<br>អង្គការដៃគូ | | |
| ៣.៣ ផលិតផ្ទាំងប៉ាណូផ្សព្វផ្សាយ | •ចំនួន ១ ស្លាកផ្ទាំងប៉ាណូ នឹងត្រូវបានផលិតសម្រាប់ផ្សព្វផ្សាយ<br>•ផែនទី១ផ្ទាំងត្រូវបានដាក់នៅកន្លែងអភិរក្ស | | | | |
| ៣.៤ ចុះល្បាតជាប្រចាំ | បទល្មើសនឹងថយចុះតាមរយៈការចុះល្បាតរបស់សហគមន៍ | | អង្គការដៃគូFAO | | |

| | | | | | |
|---|---|---|---|---|---|
| ៤.ការគ្រប់គ្រងព្រៃលិចទឹកសហគមន៍នេសាទ | • សមាជិកសហគមន៍យល់ដឹងពីសារៈសំខាន់នៃព្រៃលិចទឹក<br>• ព្រៃលិចត្រូវបានការពារដោយសមាជិកសហគមន៍នេសាទ | | រាជរដ្ឋាភិបាល<br>អង្គការដៃគូ | ២០១៧ | ២០២២ |
| ៤.១.ប្រជុំផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃលិចទឹក | សហគមន៍យល់ដឹងពីប្រយោជន៍និងថែរក្សាព្រៃលិចទឹក | | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | | |
| ៤.២.ដាំព្រៃលិចទឹកនៅកន្លែងអភិរក្ស ១,៥ ហត | • រៀបចំថ្នាលកូនឈើ<br>• ពីធីដាំកូនឈើ និងដាក់ស្លាកសញ្ញាការពារ ថែរក្សា និងការពារ | | | | |
| ៤.៣.ថែរក្សា និងការពារព្រៃលិចទឹកទំហំ ៥ ហត | ដាក់ស្លាកសញ្ញាការពារ និងផ្សព្វផ្សាយដលអ្នកពាក់ព័ន្ធទាំងអស់ | | | ២០១៧ | ២០២២ |
| ៤.៣ ចុះល្បាតជាប្រចាំ | សមាជិកសហគមន៍ ចូលរួមទប់ស្កាត់ការកាប់បផ្លាញ់ព្រៃលិចទឹក | ១.៥០០.០០០ | | | |
| ៥.ការអភិវឌ្ឍន៍វារីវប្បកម្ម<br>(ការចិញ្ចឹមត្រីក្រាញ់តាមស្រះ) | • បង្កើនត្រីសាច់សម្រាប់ហូបចុកក្នុងមូលដ្ឋាន<br>• រកប្រាក់ចំណូលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ<br>• កាត់បន្ថយសម្ពាធនេសាទលើធនធានជលផលហួសកំរិត។ | | | | |
| ៥.១.ជ្រើសរើសសមាជិកសហគមន៍ស្ម័គ្រចិត្ត | • សមាជិកស្ម័គ្រចិត្តចំនួន ១០ គ្រួសារត្រូវបានជ្រើសរើស | | | | |
| ៥.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីក្រាញ់ | សមាជិកស្ម័គ្រចិត្តនឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី | | | | |
| ៥.៣.ធ្វើស្រះចិញ្ចឹមត្រីក្រាញ់ | ចំនួន ១០ ស្រះក្នុង១ស្រះមានទំហំ ៦ម X ៤ ម ត្រូវបានជីករួចរាល់ | | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | | |
| ៥.៤.ការដាក់កូនត្រីដាក់ក្នុងស្រះ | ចំនួនកូនត្រីក្រាញ់ ២,៥០០ កូននឹងត្រូវបានផ្តល់ក្នុង១គ្រួសារ | | | | |
| ៥.៥.ត្រួតពិនិត្យតាមដាន | សមាជិកស្ម័គ្រចិត្ត នឹងធ្វើការត្រួតពិនិត្យជាប្រចាំក្នុងពេលចិញ្ចឹមត្រី | ២.០០០.០០០ | | ២០១៧ | ២០២២ |
| ៦.ការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព | • សមាជិកសហគមន៍បង្កើនប្រាក់ចំណូល<br>• ជួយកាត់បន្ថយអត្រាចំណាកស្រុក<br>• សមាជិកយល់ដឹងពីបច្ចេកទេសចិញ្ចឹមសត្វ | | | | |
| ៦.១.សមាជិកសហគមន៍ចិញ្ចឹមមាន់ និងទា | ចំនួន ១០ គ្រួសារផ្តល់បច្ចេកទេសចិញ្ចឹមមាន់ និងទាជាលក្ខណៈគ្រួសារ | | | | |
| ៦.១.១ ជ្រើសរើសកសិករស្ម័គ្រចិត្ត | សមាជិកសហគមន៍ស្ម័គ្រចិត្តចំនួន ១០ គ្រួសារត្រូវបានជ្រើសរើស | | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | | |
| ៦.១.២ វគ្គបណ្តុះបណ្តាល បច្ចេកទេសចិញ្ចឹមមាន់-ទា | ចំនួន១០ គ្រួសារនឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់-ទា | | | | |
| ៦.១.៣ ការធ្វើទ្រុងចិញ្ចឹមមាន់ ទា | ចំនួន ១០ ទ្រុង ដែលក្នុង១ទ្រុងមាន ទំហំ ២,៥ម X ៤ ម ត្រូវធ្វើរួចរាល់ | | | | |
| ៦.១.៤ ផ្តល់ពូជ និងសំភារៈ | មាន់ ទាចំនួន ៦០ ក្បាល និងសំភារៈនឹងផ្តល់ដល់សមាជិកស្ម័គ្រចិត្ត | | | | |
| ៦.១.៥ តាមដានត្រួតពិនិត្យ | សមាជិកស្ម័គ្រចិត្ត នឹងធ្វើការត្រួតពិនិត្យជាប្រចាំក្នុងពេលចិញ្ចឹមសត្វ | ៣.៥០០.០០០ | | ២០១៧ | ២០២២ |
| ៦.២.សមាជិកសហគមន៍នេសាទចិញ្ចឹមជ្រូក | ចំនួន ៥គ្រួសារផ្តល់បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ | | | | |

| | | | | | |
|---|---|---|---|---|---|
| ៦.២.១ ជ្រើសរើសកសិករស្ម័គ្រចិត្ត | សមាជិកសហគមន៍ស្ម័គ្រចិត្តចំនួន ៥ គ្រួសារត្រូវបានជ្រើសរើស | ២.៥០០.០០០ | រាជរដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០១៧ | ២០២២ |
| ៦.២.២ វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក | ចំនួន ៥ គ្រួសារ នឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក | | | | |
| ៦.២.៣ ការធ្វើទ្រុងចិញ្ចឹមជ្រូក | ចំនួន ៥ ទ្រុង ដែលក្នុង១ទ្រុងមាន ទំហំ ២,៥ម X ៤ ម ត្រូវធ្វើរួចរាល់ | | | | |
| ៦.២.៤ ផ្តល់ពូជ និងសំភារៈ | ជ្រូកមានចំនួន ១០ ក្បាល និងសំភារៈនឹងផ្តល់ដល់សមាជិកស្ម័គ្រចិត្ត | | | | |
| ៦.២.៥ តាមដានត្រួតពិនិត្យ | សមាជិកស្ម័គ្រចិត្ត នឹងធ្វើការត្រួតពិនិត្យជាប្រចាំក្នុងពេលចិញ្ចឹមសត្វ | | | | |
| ៧.ការអភិវឌ្ឍន៍កម្មវិធីចំរុះ | | | | | |
| ៧.១. បង្កើតក្រុមសន្សំប្រាក់ | សមាជិកសហគមន៍ស្ម័គ្រចិត្ត នឹងចងក្រងជាក្រុមសន្សំប្រាក់ | ៥.០០០.០០០ | គាំទ្រពីFAO រាជរដ្ឋាភិបាល សប្បុរសជន | ២០១៧ | ២០២២ |
| ៧.១.១ ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហគមន៍ | សមាជិកស្ម័គ្រចិត្តចំនួន ២៥ នាក់ នឹងត្រូវបានផ្សព្វផ្សាយទស្សនៈ | | | | |
| ៧.១.២ ការបង្កើតក្រុមសន្សំ | សមាជិកស្ម័គ្រចិត្តចំនួន ១៥ នាក់ នឹងបានបង្កើតក្រុមសន្សំ | | | | |
| ៧.១.៣ បោះឆ្នោតជ្រើសរើសប្រធាន អនុ ប្រធាន | ប្រធាន អនុ ប្រធាន លេខា និងហិរញ្ញឹកនឹងត្រូវបានបោះឆ្នោតជ្រើសរើស | | | | |
| ៧.១.៤ ការបង្កើតលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង នឹងត្រូវបានបង្កើតឡើង | | | | |
| ៧.១.៥ ការផ្តល់ទុន និងសំភារៈ | ទុន និងសំភារៈ នឹងត្រូវបានផ្តល់ក្រុមសន្សំប្រាក់ | | | | |
| ៧.១.៦ បណ្តុះបណ្តាលពីការរៀបចំថវិកានិងឯកសារ | សមាជិកចំនួន ១៥នាក់ នឹងបណ្តុះបណ្តាលពីការរៀបចំថវិកានិងឯកសារ | | | | |
| ៧.១.៧ ត្រួតពិនិត្យតាមដាន | ក្រុមសន្សំ នឹងធ្វើការត្រួតពិនិត្យជាប្រចាំក្នុងពេលអនុវត្ត | | | | |
| ៨.ការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ | • គណៈកម្មការនឹងអាចអនុវត្តសកម្មភាពក្នុងការងារ<br>• យល់ពីតួនាទីនិងភារកិច្ចរបស់ពួកគាត់ និង<br>• បង្កើនសាមគ្គីភាពនិងការទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធ | | | | |
| ៨.១.បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេររបាយការណ៍ និងលិខិតរដ្ឋបាល | កំណត់ហេតុ របាយការណ៍និងលិខិតរដ្ឋបាល នឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | រាជរដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០១៧ | ២០១៧ |
| ៨.២.បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ការគ្រប់គ្រងថវិកា នឹងត្រូវបានបណ្តុះបណ្តាល | ៣០០.០០០ | | ២០១៨ | ២០១៨ |
| ៨.៣.បណ្តុះបណ្តាលការដោះស្រាយទំនាស់ | វិធីសាស្ត្រដោះស្រាយទំនាស់នឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | | ២០១៩ | ២០១៩ |
| ៨.៤.បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ជំនាញសម្របសម្រួលនឹងត្រូវបានបណ្តុះបណ្តាល | ២០០.០០០ | | ២០២០ | ២០២០ |
| ៨.៥.បណ្តុះបណ្តាលការរៀបចំផែនការ | ការរៀបចំផែនការ នឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | | ២០២១ | ២០២១ |

| | | | | | |
|---|---|---|---|---|---|
| ៩ .ផ្សព្វផ្សាយពីច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យជលផល | - បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ<br>- កាត់បន្ថយសកម្មភាពបទល្មើសនេសាទ | | | | |
| ៩.១.ផ្សព្វផ្សាយពីច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យជលផល | ច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានពាក់ព័ន្ធជាមួយវិស័យជលផលនឹងត្រូវបានផ្សព្វផ្សាយដល់សមាជិកសហគមន៍ | ២.០០០.០០០ | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០១៧ | ២០២២ |
| ៩.២.ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង នឹងផ្សព្វផ្សាយ | ៧៥០.០០០ | | ២០១៧ | ២០២២ |
| ១០.ថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | |
| ១០.១.ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ភាគប្រចាំឆ្នាំពីសមាជិក សហគមន៍ | ១.៧៥០.០០០ | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០១៧ | ២០២២ |
| ១០.២.ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជសមាជិក | ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ៨.២៥០.០០០ | | ២០១៧ | ២០២២ |
| ១០.៣.គម្រោងស្នើសុំ៖ បដិភាគពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន និងអង្គការដៃគូ | សម្បុរសជន និងអង្គការដៃគូអភិវឌ្ឍន៍ | ៤.៧៥០.០០០ | | ២០១៧ | ២០២២ |
| ១១.ផែនការសាងសង់ស្នាក់ការ និងផ្លូវសហគមន៍ | | | | | |
| ១១.១.ជួសជុលផ្លូវ | | | | | |
| ១១.២.សាងសង់ស្នាក់ការសហគមន៍ | ស្នាក់ការរបស់សហគមន៍នេសាទត្រូវបានសាងសង់ | ២៨.០០០.០០០ | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២១ | ២០២១ |
| ១១.៣.តុ កៅអី និងទូឯកសា | សម្ភារៈកៅអី និងទូឯកសារ ត្រូវបានបំពាក់ | ២.០០០.០០០ | | ២០២២ | ២០២២ |
| ១២.ការពង្រឹងបណ្តាញសហគមន៍នេសាទនិងចូលប្រជុំផ្សេងៗ | | | | | |
| ១២.១.ប្រជុំបណ្តាញសហគមន៍នេសាទថ្នាក់ស្រុក | បណ្តាញសហគមន៍នេសាទថ្នាក់ស្រុកនឹងត្រូវបានរៀបចំប្រជុំ | ២០០.០០០ | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០១៧ | ២០២២ |
| ១២.២.ប្រជុំបណ្តាញសហគមន៍នេសាទថ្នាក់ខេត្ត | បណ្តាញសហគមន៍នេសាទថ្នាក់ខេត្តនឹងត្រូវបានរៀបចំប្រជុំ | ៤០០.០០០ | | ២០១៧ | ២០២២ |
| ១២.៣.ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទនឹងត្រូវបានរៀបចំ | ៨០.០០០ | | ២០១៧ | ២០២២ |
| ១២.៤.ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | គណៈកម្មការសហគមន៍នឹងចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ៨០.០០០ | | ២០១៧ | ២០២២ |

# តារាងកម្មវិធីការងារប្រចាំឆ្នាំ ២០១៨-២០២០

| ប្រភេទផែនការសកម្មភាព | កាលបរិច្ឆេទ ២០១៨ | | | | | | | | | | | | កាលបរិច្ឆេទ ២០១៩ | | | | | | | | | | | | កាលបរិច្ឆេទ ២០២០ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១.ការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | X | X | X | X | X | | | | | | | | X | X | X | X | X | | | | | | | X | X | X | X |
| ២.ការកែលំអដែននេសាទ | | | | | | | | | | | | | X | X | X | X | | | | | | | | | X | X | X | X | | | | | | | | |
| ៣.រៀបចំកន្លែងអភិរក្ស | | | | | | | X | X | X | X | X | X | X | X | | | | | | | X | X | X | X | X | X | X | X | | | | | | | | |
| ៤.ការគ្រប់គ្រងព្រៃលិចទឹកសហគមន៍ | | | | | X | X | X | X | X | X | X | X | | | | | X | X | X | X | X | X | X | X | | | | | X | X | X | X | X | X | X | X |
| ៥. ការធ្វើវារីវប្បកម្ម | | | | | X | | | | | | X | | | | | | X | | | | | | X | | | | | | X | | | | | | X | |
| ៦.ការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព | | | | | | | | | X | X | X | X | X | X | X | X | | | | | | | | | | | | | | | | | X | X | X | X |
| ៧.ការអភិវឌ្ឍន៍កម្មវិធីចំរុះ | | | | | | | | | | | | | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ៨.ការពង្រឹងសមត្ថភាពគណៈកម្មការ | | | | | | X | | | X | | | X | X | | X | | | X | | | | X | | X | X | | X | | | X | | | X | | | X |
| ៩.ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | | | | | | X | | | | | | X | X | | | | | X | | | | | | X | X | | | | | X | | | | | | X |
| ១០.ថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍ | | | | | | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ១១.ផែនការសាងសង់ស្នាក់ការ និងផ្លូវ | | | | | | | | | | | | X | X | X | X | X | | | | | | | | X | X | X | X | X | | | | | | | | |
| ១២.ការពង្រឹងបណ្តាញសហគមន៍ | | | | | | | | | | | | X | X | | | | | X | | | | | | X | X | | | | | X | | | | | | X |

សូមគោរពជូន

លោកមេឃុំ

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ............ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

ទួលនាងសាវ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០១៨

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

---

**លេខ** ២៥/១៨............

បានឃើញនិងគោរពជូន

លោកនាយសង្កាត់រដ្ឋបាលជលផលកំពង់ស្វាយលើ

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ............ខែ............ឆ្នាំរកា នព្វស័ក ព.ស២៥៦១

ផាត់សណ្ដាយ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៨

**មេឃុំផាត់សណ្ដាយ**

ហេង_មនោ

---

បានឃើញនិងគោរពជូន

លោកនាយផ្នែករដ្ឋបាលជលផលផាត់សណ្ដាយ

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ............ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

កំពង់ស្វាយលើ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០១៨

**នាយសង្កាត់រដ្ឋបាលជលផលកំពង់ស្វាយលើ**

---

បានឃើញនិងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ............ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

ផាត់សណ្ដាយ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០១៨

**នាយផ្នែករដ្ឋបាលជលផលផាត់សណ្ដាយ**

---

**លេខ** ............

បានឃើញនិងគោរពជូន

លោកប្រធានមន្ទីរ

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ............ខែ............ឆ្នាំរកា នព្វស័ក ព.ស២៥៦១

កំពង់ធំ ថ្ងៃទី ១៦ ខែ............ឆ្នាំ២០១៨

**នាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ**

**ប៉ែន_វណ្ណរិទ្ធ**

---

**លេខ** ............

បានឃើញនិងគោរពជូន

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ"

ថ្ងៃ............ខែ............ឆ្នាំ............ព.ស២៥៦២ កំពង់ធំ ថ្ងៃទី ២៦ ខែ............ឆ្នាំ២០១៨

**ប្រធានមន្ទីរ**

**កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ**

**ធីវ វណ្ណធីរ**

---

**លេខ**............

បានឃើញនិងឯកភាព

ថ្ងៃ............ខែ............ឆ្នាំ............ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ............ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**